**សាលាកប័ត្រព័ត៌មាន ៖** សិទ្ធិសេរីភាពខាងការជួបប្រជុំ - ទីលានប្រជាធិបតេយ្យ

**សេរីភាពមូលដ្ឋាន ៖** សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ

**ខ្លឹមសារសង្ខេប៖** ការដែលមានច្បាប់ស្តីពី ការធ្វើបាតុកម្មដោយសន្តិវិធី ក្នុងឆ្នាំ២០០៩ បង្កឱ្យមានការព្រួយបារម្ភចំពោះការបង្កើត «ទីលានប្រជាធិបតេយ្យ» ដែលជាទីតាំងកំណត់សម្រាប់រៀបចំការជួបប្រជុំដោយសន្តិវិធី អាចមានការរឹតត្បិតកាន់តែខ្លាំងឡើងចំពោះបាតុកម្មដែលធ្វើនៅទីតាំងនោះ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ មិនមែនមានតែក្តីបារម្ភនេះមួយទេ ប៉ុន្តែទីតាំងដែលត្រូវបានបង្កើតឡើង និងមានតែមួយ ដែលត្រូវបានផ្លាស់ទៅតំបន់ជាយរាជធានីភ្នំពេញ បែរជាមានការកើនឡើងនូវការមិនអនុញ្ញាតឱ្យប្រើប្រាស់ បង្កឱ្យមានផលប៉ះពាល់ដល់សិទ្ធិក្នុងការជួបប្រជុំ និងការបញ្ចេញមតិដោយសន្តិវិធី។

## សេចក្តីផ្តើម

បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី («ច្បាប់បាតុកម្ម») ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បានលើកឡើងពីក្តីកង្វល់អំពីការបង្កើតឱ្យមាន «ទីលានប្រជាធិបតេយ្យ» នៅក្នុងច្បាប់នោះ និងផលប៉ះពាល់ដែលអាចកើតមានចំពោះការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ យោងតាមមាត្រា២ នៃច្បាប់បាតុកម្ម ច្បាប់នេះមានគោលបំណង «ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី» ខណៈពេលដែលសៀវភៅណែនាំការអនុវត្តដែលភ្ជាប់មកជាមួយចែងថា «ច្បាប់នេះជាច្បាប់ដែលផ្តល់លទ្ធភាពនិងធានាថាការធ្វើបាតុកម្ម អាចប្រព្រឹត្តទៅដោយសន្តិវិធី»។ ប៉ុន្តែគួរឱ្យសោកស្តាយ ដែលមិនមានការអនុវត្តបែបនេះចាប់តាំងពីច្បាប់បាតុកម្មបានចូលជាធរមាន។ ច្បាប់នេះមិនត្រឹមតែត្រូវបានប្រើប្រាស់ដើម្បីរារាំងការជួបជុំ និងបាតុកម្មដោយសន្តិវិធីនៅទីលានប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងមានការរឹតត្បិត និងបដិសេធកាន់តែខ្លាំងទៅលើការប្រើប្រាស់ទីលានប្រជាធិបតេយ្យផងដែរ ។

ប្រជាធិបតេយ្យអាចមានជីវិតតាមរយៈការចូលរួមក្នុងសង្គមជារៀងរាល់ថ្ងៃ និងទាមទារឱ្យបុគ្គលម្នាក់ៗអាចបញ្ចេញទស្សនៈរបស់ខ្លួន ជួបជុំដោយសន្តិវិធី រៀបចំ និងចូលរួមក្នុងការជជែកដេញដោលជាសាធារណៈ។ នៅពេលដែលកម្ពុជាខិតជិតដល់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០២៧ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០២៨ ការការពារសេរីភាពជាមូលដ្ឋានពិតជាមានសារៈសំខាន់។ ហេតុនេះ ការរឹតត្បិតលើការជួបជុំដោយសន្តិវិធី អាចបង្កហានិភ័យដល់លំហប្រជាធិបតេយ្យ ដែលប្រជាពលរដ្ឋកម្ពុជាអាចអនុវត្តតួនាទី និងចូលរួមប្រកបដោយអត្ថន័យក្នុងជីវភាពសាធារណៈ និងឆាកនយោបាយ ដោយធ្វើឱ្យលទ្ធិប្រជាធិបតេយ្យនៅសល់ត្រឹមតែសកម្មភាពនៃការបោះឆ្នោតតែមួយប៉ុណ្ណោះ។ ការបោះឆ្នោតនាពេលខាងមុខនេះ គឺជាឱកាសដើម្បីគោរពសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ការជួបជុំ និងការបង្កើតសមាគម ដូចដែលលោក ថូម៉ាស

អេនឌ្រូ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើង។[1]

## សិទ្ធិសេរីភាពខាងការជួបជុំ និងសេរីភាពខាងការបញ្ចេញមតិក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ

សិទ្ធិសេរីភាពក្នុងការជួបប្រជុំ គឺជាសិទ្ធិមនុស្សមូលដ្ឋានដែលអនុញ្ញាតឱ្យបុគ្គលគ្រប់រូបបញ្ចេញទស្សនៈរបស់ខ្លួនជាសមូហភាពជុំវិញជំនឿ ឬគំនិតអំពីសង្គមរបស់ពួកគេ និងការអនុវត្តស្វ័យភាពបុគ្គលក្នុងការរួបរួមសាមគ្គីជាមួយអ្នកដទៃ។ សិទ្ធិទាំងនេះត្រូវបានភ្ជាប់ទៅនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ក៏ដូចជាការប្រមូលផ្តុំដោយសន្តិវិធីក្នុងគោលបំណង ឬបុព្វហេតុជាក់លាក់មួយជាទម្រង់នៃការបញ្ចេញមតិដោយសេរី។ ទាំងនេះជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ សិទ្ធិសេរីភាពខាងការបញ្ចេញមតិនិងការជួបជុំត្រូវបានការពារ និងលើកកម្ពស់នៅក្នុងច្បាប់កម្ពុជា។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ») ចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិនិងសេរីភាពខាងការប្រជុំ។ មាត្រា៣៥ ចែងថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ។ មាត្រា៣១ ចែងថា កម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញានិងអនុសញ្ញានានាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ជាលទ្ធផល បទប្បញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ត្រូវបានធានា និងអាចអនុវត្តបានដូចច្បាប់ជាតិ។[2] មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់បុគ្គលគ្រប់រូប ខណៈដែលមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីសិទ្ធិសេរីភាពក្នុងការជួបប្រជុំ។

## ការវិភាគទៅលើច្បាប់បាតុកម្ម ទីលានប្រជាធិបតេយ្យ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ

យោងតាមមាត្រា៣ នៃច្បាប់បាតុកម្ម ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះ «រាល់ការប្រមូលផ្តុំគ្នា ឬការដង្ហែក្បួនធ្វើបាតុកម្មដោយសន្តិវិធី» ប៉ុន្តែមិនអនុវត្តចំពោះការជួបប្រជុំមួយចំនួនដូចជាយុទ្ធនាការឃោសនាបោះឆ្នោត ការប្រមូលផ្តុំពាក់ព័ន្ធនឹងវិវាទការងារ និងការហែក្បួនពុយហយាត្រា ក្បួនដង្ហែសព និង«ការប្រមូលផ្តុំដទៃទៀតក្នុងគោលបំណងបម្រើសាសនា សិល្បៈ វប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីជាតិ»។ ការមិនរាប់បញ្ចូល

---

[1] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស៖ សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្មរបស់លោក ថូម៉ាស អេនឌ្រូ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៦

[2] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧, ទំព័រ២៖ ពាក្យ «ច្បាប់» ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅមានជាធរមាន ហើយនឹងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់មកហើយ។

ទាំងនេះ ហាក់មិនស៊ីសង្វាក់គ្នាជាមួយនឹងការការពារយ៉ាងទូលំទូលាយចំពោះការជួបជុំដោយសន្តិវិធី ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលរួមមាន «ការធ្វើបាតុកម្ម ការតវ៉ា ការប្រជុំ ការដើរដង្ហែក្បួន ការជួបជុំទ្រង់ទ្រាយធំ ការអង្គុយតវ៉ា ការជួបជុំអុជទៀន និងការជួបជុំភ្លាមៗដោយមិនបានគ្រោងទុកជាមុន»។ គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា ការជួបជុំអាចធ្វើឡើងក្នុងគោលបំណងផ្សេងៗគ្នាជាច្រើន រួមទាំងការបញ្ចេញទស្សនៈ ការបង្ហាញជំហរលើបញ្ហាជាក់លាក់ ការផ្លាស់ប្តូរគំនិតយោបល់ ឬការបង្ហាញពីសាមគ្គីភាព ឬអត្តសញ្ញាណរបស់ក្រុម ហើយក៏អាចធ្វើឡើងក្នុងគោលបំណងជាការកម្សាន្ត វប្បធម៌ សាសនា ឬពាណិជ្ជកម្មផងដែរ ខណៈដែលនៅតែទទួលបានការការពារក្រោមមាត្រា ២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[3]

មាត្រា៤ នៃច្បាប់បាតុកម្មចែងថា «បាតុកម្មដោយសន្តិវិធី» សំដៅលើ «ការប្រមូលផ្តុំគ្នា ឬការដង្ហែក្បួនដោយមនុស្សមួយក្រុម ដើម្បីទាមទារ តវ៉ា ឬសម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬឆន្ទៈរបស់ក្រុមខ្លួនតាមរូបភាព ឬមធ្យោបាយផ្សេងៗដោយសន្តិវិធី»។ ច្បាប់នេះមិនបានចែងអំពីភាពខុសគ្នារវាង «ការប្រមូលផ្តុំនិងការហែក្បួនដោយសន្តិវិធី» និង «ការជួបប្រជុំដោយសន្តិវិធី» ឡើយ។

ចំពោះការជួបប្រជុំដោយសន្តិវិធីដែលមានមនុស្សចូលរួមយ៉ាងច្រើនបំផុតត្រឹម ២០០នាក់ មាត្រា១៤ ចែងថា អាចប្រារព្ធធ្វើនៅទីលានប្រជាធិបតេយ្យ ដោយតម្រូវឱ្យមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អាជ្ញាធររាជធានី ឬខេត្ត យ៉ាងហោចណាស់ឱ្យបានមុន ១២ ម៉ោង។ យោងតាមសៀវភៅណែនាំការអនុវត្តច្បាប់បាតុកម្ម កន្លែងបញ្ចេញមតិសាធារណៈត្រូវតែជា «បរិវេណ ឬមជ្ឈមណ្ឌលដែលសាធារណជនទូទៅងាយស្តាប់ឮ និងមើលឃើញ» និង «មិនគួរស្ថិតនៅកន្លែងមួយដែលស្ងាត់ជ្រងំនោះទេ បាតុករមានសិទ្ធិឱ្យគេដឹងឮនូវការទាមទាររបស់ខ្លួន»។ លើសពីនេះ ច្បាប់បាតុកម្ម ក៏បានចែងផងដែរថា រាជធានី និងខេត្តនីមួយៗត្រូវបង្កើតឱ្យមានទីលានប្រជាធិបតេយ្យឱ្យបានត្រឹមថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១០ ។ ទោះជាយ៉ាងនេះក៏ដោយ រយៈពេលជាង ១៥ ឆ្នាំក្រោយមក ម.ស.ម.ក បានដឹងថាមានទីលានប្រជាធិបតេយ្យនៅរាជធានីភ្នំពេញតែមួយប៉ុណ្ណោះ។

ម.ស.ម.ក ក៏បានកត់សម្គាល់ផងដែរថា បទបញ្ញត្តិមួយចំនួននៃច្បាប់បាតុកម្ម ពាក់ព័ន្ធនឹងទីលានប្រជាធិបតេយ្យ គឺផ្ទុយទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ឬមិនត្រូវបានអនុវត្ត ជាពិសេសទាក់ទងនឹងទីតាំង និងការផ្តល់ការអនុញ្ញាត។

- **ទីកន្លែង**

ការកំណត់ទីតាំងជាក់លាក់មួយសម្រាប់រៀបចំការជួបជុំដោយសន្តិវិធី ក្លាយជាបញ្ហានៅពេលដែលការកំណត់នេះបានក្លាយទៅជាច្បាប់ ហើយការជួបប្រជុំដែលមិនរៀបចំនៅទីតាំងនេះត្រូវបានហាមឃាត់ដោយសារតែមូលហេតុនេះ។ នៅក្នុងសេចក្តីអធិប្បាយទូទៅលេខ៣៧ គណៈកម្មធិការសិទ្ធិមនុស្សអះអាងថា ជាគោលការណ៍ទូទៅ រាល់ការជួបប្រជុំដោយសន្តិវិធីអាចត្រូវបានធ្វើឡើងនៅគ្រប់ទីកន្លែងដែលសាធារណជនអាចចេញ

---

[3] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីអធិប្បាយទូទៅលេខ ៣៧ (CCPR/C/GC/37) ១៧ កញ្ញា ២០២០ កថាខណ្ឌទី៦

ចូល ឬគួរមានសិទ្ធិចេញចូល ដោយថា «មិនអាចមានការហាមប្រាមលើការជួបប្រជុំទាំងអស់... រាល់កន្លែងសាធារណៈទាំងអស់ លើកលែងតែកន្លែងជាក់លាក់មួយស្ថិតក្នុងទីក្រុង ឬក្រៅបេះដូងនៃទីក្រុង»។[4] ការជួបប្រជុំគ្នាគឺជាការប្រើប្រាស់ស្របច្បាប់នូវទីសាធារណៈ ហើយដោយសារការជួបប្រជុំទាំងនោះអាចពាក់ព័ន្ធនឹងកម្រិតជាក់លាក់មួយនៃការរំខានជាស្រេចរួចទៅហើយដល់ជីវិតធម្មតា ដូច្នេះ រាល់ការរំខានត្រូវតែមានហេតុផលសមស្រប។[5] ម.ស.ម.ក បានកត់ត្រាតាំងពីឆ្នាំ២០១៦ មកថា ការជូនដំណឹងដល់អាជ្ញាធររាជធានីភ្នំពេញអំពីការជួបជុំដែលបានគ្រោងធ្វើឡើងនៅទីតាំងផ្សេងក្រៅពីទីលានប្រជាធិបតេយ្យ ជារឿយៗត្រូវបានអាជ្ញាធរឆ្លើយតបថាមិនអាចប្រព្រឹត្តទៅនៅទីតាំងដែលបានគ្រោងទុកទេ ហើយណែនាំថាការជួបជុំនោះគួរតែធ្វើឡើងនៅទីលានប្រជាធិបតេយ្យវិញ។[6]

ទោះបីជាមានបទប្បញ្ញត្តិនៃច្បាប់បាតុកម្មបានចែងយ៉ាងច្បាស់ ដោយតម្រូវឱ្យមានទីលានប្រជាធិតេយ្យនៅចំកណ្តាលទីក្រុងក៏ដោយ ការផ្លាស់ប្តូរទីលានប្រជាធិតេយ្យនៅរាជធានីភ្នំពេញនៅឆ្នាំ២០១៧ បានប្រាសចាកនឹងបទបញ្ញត្តិនេះ។ ទីលានប្រជាធិបតេយ្យមានទីតាំងដើមស្ថិតនៅក្នុងខណ្ឌដូនពេញ នៅជិតស្ថាប័នជាតិ និងស្ថានទូតនានា តែទីតាំងនេះត្រូវបានផ្លាស់ប្តូរទៅកាន់ទីកន្លែងដែលមានចម្ងាយប្រមាណប្រាំគីឡូម៉ែត្រពីកណ្តាលក្រុង ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ដែលជាតំបន់ហ៊ុំព័ទ្ធដោយឃ្លាំងទំនិញ និងអគារឧស្សាហកម្ម។ អាជ្ញាធរបានលើកយកហេតុផលអំពីផលប៉ះពាល់ដល់អាជីវកម្ម ទេសចរណ៍ និងការបង្កឱ្យមាន «ភាពអនាធិបតេយ្យ» ជាមូលហេតុនៃការផ្លាស់ប្តូរទីលានប្រជាធិបតេយ្យចេញពីទីតាំងដែលបានបង្កើតឡើងពីដំបូង។ ការផ្លាស់ប្តូរទីតាំងទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ មិនត្រឹមតែផ្ទុយពីច្បាប់បាតុកម្មប៉ុណ្ណោះទេ ថែមទាំងផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលចែងថា «ការជួបប្រជុំដោយសន្តិវិធី មិនគួរត្រូវបានរុញឱ្យធ្វើនៅតំបន់ដាច់ស្រយាល ដែលបាតុកម្មមិនអាចទាក់ទាញចំណាប់អារម្មណ៍របស់សមត្ថកិច្ចដែលមានភារកិច្ចដោះស្រាយ និងសាធារណជនឡើយ»។[7]

- **ការអនុញ្ញាត**

យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការប្រមូលផ្តុំ ឬការធ្វើបាតុកម្មដោយសន្តិវិធី មិនចាំបាច់មានការអនុញ្ញាតពីអាជ្ញាធរនោះទេ។ នៅក្នុងករណីជាច្រើន ការតម្រូវឱ្យមានការអនុញ្ញាតអាចធ្វើឱ្យប៉ះពាល់ដល់គោលបំណងពិតប្រាកដ និងគោលការណ៍នៃការតវ៉ា។ ខណៈពេលដែលមាត្រា៥ ដល់មាត្រា៧ នៃច្បាប់បាតុកម្ម ប្រើពាក្យ «ត្រូវ» ទាក់ទងទៅនឹងការដាក់លិខិតជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធ ហើយត្រូវបានបញ្ជាក់នៅក្នុងមាត្រា២០ ដែលចែងថា «ទោះបីជាបាតុកម្មប្រព្រឹត្តទៅដោយសន្តិវិធីក៏ដោយ ក៏ប៉ុន្តែបើមិនបានដាក់លិខិតជូនដំណឹងស្របតាមមាត្រា៥ មាត្រា៦ និងមាត្រា១៤ នៃច្បាប់នេះ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់វិធានការបញ្ឈប់

---

[4] ដូចខាងលើ, កថាខណ្ឌទី៥៥

[5] ដូចខាងលើ, កថាខណ្ឌទី៤៧

[6] ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន (ខែសីហា ឆ្នាំ២០១៧), ទំព័រទី៣០

[7] CCPR/C/GC/37 កថាខណ្ឌទី៥៣-៥៥

បាតុកម្មនេះបាន»។ ជាងនេះទៅទៀត ផ្នែកទី២ (១) នៃសៀវភៅណែនាំអំពីការអនុវត្តច្បាប់បាតុកម្មទាក់ទងនឹងមាត្រា៥ បានរួមបញ្ចូលការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ពីពាក្យ «ត្រូវ» ដោយបញ្ជាក់ថា «បុគ្គលទាំងឡាយណាដែលមានបំណងរៀបចំបាតុកម្មដោយសន្តិវិធីនៅទីកន្លែងសាធារណៈណាមួយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធររាជធានី ឬខេត្តមានសមត្ថកិច្ចគ្រប់គ្រងទីកន្លែងនោះ»។

ប្រព័ន្ធជូនដំណឹងគួរតែបម្រើគោលបំណងដែលការអនុញ្ញាតឱ្យអាជ្ញាធរបំពេញកាតព្វកិច្ចវិជ្ជមានរបស់ខ្លួនក្នុងការសម្របសម្រួលឱ្យមានការជួបប្រជុំដោយសន្តិវិធី និងការពារសិទ្ធិរបស់អ្នកដទៃ។[8] ដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ «របបជូនដំណឹងក៏មិនត្រូវបំប្លែការអនុវត្តទៅជារបបសុំការអនុញ្ញាតដែរ»។[9] ទោះបីជាដូចនេះក៏ដោយ ករណីបែបនេះមាននៅក្នុងច្បាប់បាតុកម្មរួចទៅហើយ។ ការតម្រូវឱ្យមានការអនុញ្ញាតនៅក្នុងច្បាប់ជាតិ គឺមិនស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលថា «ច្បាប់ជាតិមិនគួរតម្រូវឱ្យមានការអនុញ្ញាតជាមុនដើម្បីឱ្យមានការប្រមូលផ្តុំ និងត្រូវបើកឱ្យមានការប្រមូលផ្តុំដោយឯកឯងផងដែរ»។[10]

នៅក្នុងការឃ្លាំមើលការអនុវត្តសេរីភាពមូលដ្ឋានរយៈពេល៩ ឆ្នាំ មក ម.ស.ម.ក បានកត់សម្គាល់ឃើញមានការរឹតត្បិតទៅលើការជួបជុំដោយសន្តិវិធីនៅទីលានប្រជាធិបតេយ្យបានកើតឡើងបន្ថែមទៀត ដោយអាជ្ញាធរបានឆ្លើយតបទៅនឹងអ្នករៀបចំថាការប្រមូលផ្តុំរបស់ពួកគេមិនអាចប្រព្រឹត្តិទៅបានទេ ទោះបីជានៅទីលានប្រជាធិបតេយ្យក៏ដោយ។[11] ពេលខ្លះ ពួកគេក៏ត្រូវបានរាំងពីការចូលទៅកាន់ទីតាំងនោះផងដែរ។ នៅខែកញ្ញា ឆ្នាំ ២០២០ ទីលានប្រជាធិបតេយ្យត្រូវបានដាក់រនាំងឃាំង និងយាមកាមដោយមន្ត្រីនគរបាល ដើម្បីរារាំងមនុស្សមួយក្រុមដែលមានបំណងចូលទៅសម្តែងមតិ តវ៉ាទៅនឹងការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស។ រដ្ឋបាលរាជធានីភ្នំពេញបានអះអាងថា នេះជាភាពចាំបាច់ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានធ្វើការរិះគន់ចំពោះការរឹតត្បិតនេះ។ នៅខែមេសា ឆ្នាំ២០២៤ រដ្ឋបាលរាជធានីភ្នំពេញបាន រារាំងការប្រមូលផ្តុំដោយសន្តិវិធីរបស់គណបក្សកម្លាំងជាតិ ដែលគ្រោងធ្វើឡើងនៅទីលានប្រជាធិបតេយ្យក្នុងគោលបំណងទាមទារឱ្យមានការដោះលែងសមាជិកគណបក្សរបស់ខ្លួនដែលជាប់ពន្ធនាគារ។

---

[8] CCPR/C/GC/37 កថាខណ្ឌទី៧០-៧៤

[9] CCPR/C/GC/37 កថាខណ្ឌទី៧៣

[10] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, គោលការណ៍គំរូសម្រាប់មន្ត្រីអនុវត្តច្បាប់ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សក្នុងបរិបទនៃការជួបប្រជុំដោយសន្តិវិធី (A/HRC/55/60) ថាខណ្ឌទី១៨

[11] ម.ស.ម.ក, បាយការណ៍ឆ្នាំ២០២៣ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែមេសា ឆ្នាំ២០២៤), ទំព័រ៣៣-៣៤
ម.ស.ម.ក, របាយការណ៍ឆ្នាំ២០២២ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែកញ្ញា ឆ្នាំ២០២៣), ទំព័រ២៩
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទី៦ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែមេសា ឆ្នាំ២០២២), ទំព័រ៣៦
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទី៥ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែមេសា ឆ្នាំ២០២១), ទំព័រ៣៩-៤០
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទី៤ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែកក្កដា ឆ្នាំ២០២០), ទំព័រ៤៥-៤៨
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទី៣ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែកក្កដា ឆ្នាំ២០១៩), ទំព័រ៤៨-៤៩
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទី២ នៃការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា (ខែកញ្ញា ឆ្នាំ២០១៨), ទំព័រ៥០-៥២
ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំលើកទី១ នៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន(ខែសីហា ឆ្នាំ២០១៧), ទំព័រ២៨-៣១

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥ រដ្ឋបាលរាជធានីភ្នំពេញបានបដិសេធគម្រោងប្រារព្ធទិវាពលកម្មអន្តរជាតិ ១ឧសភា របស់គណបក្សកម្លាំងជាតិដែលគ្រោងធ្វើឡើងនៅទីលានប្រជាធិបតេយ្យក្រោមហេតុផលថា ទីលានប្រជាធិបតេយ្យមិនមែនជាតាំងសម្រាប់ប្រារព្ធពិធីនានាឡើយ ដូច្នេះពួកគេមិនអាចប្រើប្រាស់ទីតាំងនោះបានទេ។ ពីរថ្ងៃក្រោយមក អាជ្ញាធររាជធានីភ្នំពេញបានប្រើហេតុផលដូចគ្នា ដើម្បីឆ្លើយតបនឹងលិខិតជូនដំណឹងរបស់ក្រុមអង្គការសង្គមស៊ីវិល ដែលមានបំណងប្រើប្រាស់ទីលានប្រជាធិបតេយ្យដើម្បីប្រារព្ធទិវាពលកម្មអន្តរជាតិ។ ក្រុមអង្គការសង្គមស៊ីវិលបានដាក់លិខិតម្តងទៀត ដោយធ្វើការបញ្ជាក់ថាពួកគេមានបំណងធ្វើការសម្តែងមតិអហិង្សាជាសាធារណៈ ប៉ុន្តែត្រូវរដ្ឋបាលរាជធានីភ្នំពេញបានឆ្លើយតប នៅក្នុងកិច្ចប្រជុំជាមួយតំណាងអង្គការសង្គមស៊ីវិលថាលិខិតជូនដំណឹងដែលដាក់ទៅកាន់រដ្ឋបាលរាជធានីភ្នំពេញមិនត្រឹមត្រូវតាមនីតិវិធី និងបានស្នើឱ្យក្រុមសង្គមស៊ីវិលរៀបចំកម្មវិធីនៅទីស្នាក់ការរបស់ខ្លួនវិញ។ ចុងក្រោយ ក្រុមអង្គការសង្គមស៊ីវិលត្រូវបានអនុញ្ញាតឱ្យរៀបចំកម្មវិធីនៅទីតាំងផ្សេងជំនួសវិញ។ ការព្រមានអំពីការប្រារព្ធពិធី និងការណែនាំឱ្យរៀបចំការសម្តែងមតិនៅទីស្នាក់ការអ្នករៀបចំកម្មវិធីបែបនេះ ក៏ត្រូវបានលើកឡើងកាលពីខែកញ្ញា ឆ្នាំ២០២៤ ជាការឆ្លើយតបទៅនឹងលិខិតជូនដំណឹងរបស់សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (សមាគមគ្រូបង្រៀន) ដែលមានបំណងប្រើប្រាស់ទីលានប្រជាធិបតេយ្យផងដែរ បើទោះបីជាសមាគមនេះបានប្រារព្ធទិវាគ្រូបង្រៀនពិភពលោកនៅទីនោះជារៀងរាល់ឆ្នាំក៏ដោយ។

ចាប់តាំងពីសង្គ្រាមព្រំដែនកម្ពុជា - ថៃ បានផ្ទុះឡើងនៅក្នុងខែកក្កដា ឆ្នាំ២០២៥ មិនមានការអនុញ្ញាតឱ្យប្រើប្រាស់ទីលានប្រជាធិបតេយ្យម្តងណាឡើយ។ ម.ស.ម.ក បានកត់ត្រាកម្មវិធីជាច្រើនដែលគ្រោងរៀបចំឡើងនៅទីលានប្រជាធិបតេយ្យត្រូវបានអាជ្ញាធរបដិសេធ។ នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ សមាគមគ្រូបង្រៀនបានជូនដំណឹងអាជ្ញាធររាជធានីភ្នំពេញ អំពីការប្រារព្ធទិវាគ្រូបង្រៀនពិភពលោកនៅទីលានប្រជាធិបតេយ្យនៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៥ ដោយមានអ្នកចូលរួមប្រមាណ ១៥០ នាក់។ សាលារាជធានីភ្នំពេញបានអញ្ជើញអ្នករៀបចំដើម្បីជជែកអំពីផែនការនៅថ្ងៃទី៣០ ខែកញ្ញា។ អាជ្ញាធរលើកឡើងថា ដោយសារស្ថានភាពប្រទេសកម្ពុជាកំពុងតែជួបបញ្ហាប្រឈមពីការឈ្លានពានរបស់ប្រទេសថៃ ដូច្នេះស្នើសុំឱ្យសមាគមគ្រូបង្រៀនប្រារព្ធទិវានេះនៅការិយាល័យរបស់ខ្លួនវិញ។ ស្រដៀងគ្នា ហេតុផលដដែលនេះត្រូវបានប្រើដើម្បីបដិសេធសំណើរបស់ក្រុមអង្គការសង្គមស៊ីវិលចំនួន ២២ ពីការរៀបចំពិធីរំលឹកខួបលើកទី ៣៤ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅទីលានប្រជាធិបតេយ្យ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៥។ ជំនួសមកវិញ អាជ្ញាធររាជធានីភ្នំពេញបានណែនាំឱ្យអង្គការសង្គមស៊ីវិលទាំងនោះរៀបចំកម្មវិធីនេះនៅឯការិយាល័យរបស់ពួកគេ ឬនៅទីកន្លែងឯកជនផ្សេងទៀត។[12] នៅខែតុលា ឆ្នាំ ២០២៥ គណបក្សកម្លាំងជាតិ ក៏មានបំណងរៀបចំពិធីរំលឹកខួបលើកទី ៣៤ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅទីលានប្រជាធិបតេយ្យដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ គណបក្សនេះត្រូវបានហាមឃាត់ក្នុងការរៀបចំព្រឹត្តិការណ៍នៅទីតាំងដែលខ្លួនបានគ្រោងទុក

[12] កំណត់ហេតុប្រជុំស្តីពី សំណើសុំការអនុញ្ញាតរៀបចំពិធីអបអរសាទរខួបលើកទី៣៤ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅទីលានប្រជាធិបតេយ្យ របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន២២

ដោយមិនមានការបញ្ជាក់ពីហេតុផលជាក់លាក់ណាមួយសម្រាប់ការបដិសេធនេះទេ ប៉ុន្តែគណបក្សត្រូវបានស្នើឱ្យរៀបចំកម្មវិធីនៅឯការិយាល័យរបស់ខ្លួនវិញ។

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការលើកកម្ពស់សិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិស្ត្រី បានដាក់លិខិតជូនដំណឹងទៅរដ្ឋបាលរាជធានីភ្នំពេញ អំពីបំណងប្រើប្រាស់ទីលានប្រជាធិបតេយ្យ សម្រាប់រៀបចំទិវាអន្តរជាតិនារី លើកទី១១៥ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៦។ ពួកគេគ្រោងរៀបចំដោយមានមនុស្សចំនួន ៥០០ នាក់ចូលរួមក្នុងព្រឹត្តិការណ៍នេះ ប៉ុន្តែត្រូវបានអាជ្ញាធររាជធានីភ្នំពេញបដិសេធតាមរយៈលិខិតផ្ញើជូនក្រុមអ្នករៀបចំនៅថ្ងៃទី៤ ខែមីនា។ នៅថ្ងៃទី៦ ខែមីនា ក្រុមអង្គការសង្គមស៊ីវិលបានចេញលិខិតចំហ ប្រកាសថា ការជួបជុំនឹងនៅតែប្រព្រឹត្តទៅតាមការគ្រោងទុក ហើយបានស្នើឱ្យអាជ្ញាធរអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការពារសណ្តាប់ធ្នាប់នៅទីលានប្រជាធិបតេយ្យនៅថ្ងៃទី៨ ខែមីនា។ បន្ទាប់ពីលិខិតចំហនោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ រដ្ឋបាលរាជធានីភ្នំពេញបានអញ្ជើញក្រុមអង្គការសង្គមស៊ីវិលមកធ្វើការប្រជុំគ្នានៅថ្ងៃទី៧ ខែមីនា ដើម្បីពិភាក្សាអំពីផែនការនេះ។ ជាលទ្ធផល ពួកគេត្រូវបានអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍នេះនៅទីតាំងផ្សេងមួយទៀត។

គួរកត់សំគាល់ថា ការរឹតត្បិតចំពោះការប្រើប្រាស់ទីលានប្រជាធិបតេយ្យកំពុងកើតឡើងនៅក្នុងបរិយាកាសដែលការហែក្បួនដោយសន្តិវិធី ជាពិសេសការដើរដង្ហែដើម្បីលើកឡើងពីទុក្ខលំបាក ឬតស៊ូមតិដើម្បីសិទ្ធិនៅតែបន្តប្រឈមមុខនឹងការរឹតត្បិតយ៉ាងតឹងរ៉ឹង។ ថ្មីៗនេះ នៅថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២៦ ដែលជាទិវាពលកម្មអន្តរជាតិ កម្មករ និងតំណាងសហជីពប្រមាណ ២០០នាក់ ដែលព្យាយាមដើរដង្ហែទៅកាន់ស្ថានទូត និងស្ថាប័នរដ្ឋមួយចំនួនក្នុងរាជធានីភ្នំពេញ ត្រូវបានកងកម្លាំងសន្តិសុខខណ្ឌរារាំង។ អាជ្ញាធរបានប្រាប់អ្នករៀបចំកម្មវិធីថា មានតែមនុស្សប្រហែល ១០នាក់ប៉ុណ្ណោះដែលត្រូវអនុញ្ញាតឱ្យដើរ និងដាក់ញត្តិ។ ការប៉ុនប៉ងដើររបស់អ្នកចូលរួមពីស្ថានទូតអាមេរិកទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក៏ត្រូវបានរារាំង។ ក្នុងរយៈពេលនេះ ការដើរដង្ហែទ្រង់ទ្រាយធំលើបញ្ហាផ្សេងៗទៀតត្រូវបានអនុញ្ញាត ដូចជាការដើរដង្ហែដើម្បីសន្តិភាពទាក់ទងនឹងជម្លោះព្រំដែនកម្ពុជា-ថៃ កាលពីឆ្នាំ២០២៥។ ការអនុវត្តខុសៗគ្នានេះ បង្កឱ្យមានការព្រួយបារម្ភទាក់ទងនឹងភាពស៊ីសង្វាក់គ្នា និងការមិនរើសអើងក្នុងការអនុវត្តវិធានការរឹតត្បិតលើការជួបជុំដោយសន្តិវិធី។ នេះក៏បានសបញ្ជាក់ផងដែរ អំពីផលប៉ះពាល់ចំពោះការកំណត់ទីកន្លែងជាក់លាក់សម្រាប់ការសម្តែងមតិដោយសន្តិវិធី និងការប្រើប្រាស់ទីតាំងនោះ ព្រោះការកំណត់បែបនោះអាចនាំឱ្យមានការរឹតត្បិតដល់ការជួបប្រជុំ និងការដើរហែក្បួនដែលធ្វើឡើងនៅទីតាំងផ្សេងទៀត។

ផ្អែកតាមបទពិសោធន៍របស់អង្គការសង្គមស៊ីវិល ដែលបានទាក់ទងជាមួយអាជ្ញាធរដើម្បីសម្រួលដល់ការជួបជុំគ្នានៅទីលានប្រជាធិបតេយ្យប្រព្រឹត្តិទៅបាន អាជ្ញាធរតែងប្រើយុទ្ធសាស្ត្រដែលហាក់ដូចជាមានបំណងបំភិតបំភ័យដល់បុគ្គលិក និងសមាជិករបស់អង្គការសង្គមស៊ីវិល។ ឧទាហរណ៍ អាជ្ញាធរកោះប្រជុំជាមួយតំណាងអង្គការសង្គមស៊ីវិល ហើយតំណាងអង្គការសង្គមស៊ីវិលចូលរួមក្នុងកិច្ចប្រជុំមានចំនួនតិច ចំណែកអ្នកចូលរួមដែលជាតំណាងពីរដ្ឋាភិបាលមានចំនួនច្រើនលើសលុប ដែលមួយចំនួនធំ ជាមន្ត្រីមានតួនាទីខ្ពស់។ បទ

ពិសោធន៍មួយទៀតរបស់អង្គការសង្គមស៊ីវិលគឺ ពួកគេត្រូវបានអញ្ជើញមកប្រជុំដើម្បីស្តាប់ពីការសម្រេច និងការពន្យល់របស់អាជ្ញាធរ ដែលជារឿយៗ តំណាងអង្គការសង្គមស៊ីវិលមិនមានពេលគ្រប់គ្រាន់ដើម្បីបញ្ចេញមតិយោបល់ ឬចូលរួមលើពិភាក្សាលើសេចក្តីសម្រេចនោះទេ។ ក្តីបារម្ភពាក់ព័ន្ធនឹងការអនុវត្តបែបនេះត្រូវបានអតីតអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា គឺលោក វីទីត ម៉ុនតាប៊ិន លើកឡើងថា ក្រុមនេះបានរងការគំរាមកំហែង ហើយនៅក្នុងឆ្នាំ២០២៥ លោកបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឱ្យណែនាំអាជ្ញាធរមូលដ្ឋានដើម្បីបញ្ឈប់ការតាមដាន និងការគំរាមកំហែងដល់ភាគីពាក់ព័ន្ធនានាដែលចូលរួមធ្វើការជាមួយអង្គការសង្គមស៊ីវិល។[13] យុទ្ធសាស្ត្រទាំងនេះទំនងជាមានបំណងឱ្យអង្គការសង្គមស៊ីវិលធ្វើការស្នើសុំការយល់ព្រមពីអាជ្ញាធរដើម្បីឱ្យការជួបប្រជុំនៅទីលានប្រជាធិបតេយ្យអាចប្រព្រឹត្តិទៅបាន ដែលនេះមិនស្របនឹងច្បាប់និងបទដ្ឋានសិទ្ធិមនុស្សឡើយ។

## សេចក្តីសន្និដ្ឋាន

អស់រយៈពេលច្រើនឆ្នាំមកហើយ ដែលច្បាប់បាតុកម្មបានចូលជាធរមាន មិនត្រឹមតែមានក្តីបារម្ភអំពីការប្រើប្រាស់ទីតាំងទីលានប្រជាធិបតេយ្យដោយមិនត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែការប្រើប្រាស់ទីកន្លែងដែលបានកំណត់នេះកាន់តែជួបការលំបាកថែមទៀតសម្រាប់អ្នកដែលមានបំណងសម្តែងមតិ និងការជួបជុំនៅទីតាំងនោះ។ ដោយហេតុថា អ្នករៀបចំការសម្តែងមតិត្រូវជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធអំពីផែនការរបស់ខ្លួន ដូច្នេះការជួបប្រជុំអាចប្រព្រឹត្តទៅដោយសន្តិវិធី និងមានការសម្របសម្រួលពីសំណាក់អាជ្ញាធរ ដែលពួកគេមានកាតព្វកិច្ចដូចដែលបានប្តេជ្ញាតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា។ ជំនួសមកវិញ អ្នករៀបចំបែរជា«មិនទទួលបានការអនុញ្ញាត» ក្នុងការប្រើប្រាស់ទីលានប្រជាធិបតេយ្យ ដែលផ្ទុយទៅនឹងស្មារតីនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលថា ការជួបជុំដោយសន្តិវិធីមិនតម្រូវឱ្យមានការអនុញ្ញាត។ ការបដិសេធនូវការប្រើប្រាស់ទីលានប្រជាធិបតេយ្យ បានបង្កជាក្តីបារម្ភកាន់តែខ្លាំងឡើង ស្របពេលដែលមានទីលានប្រជាធិបតេយ្យតែមួយគត់ ទោះបីជាច្បាប់បាតុកម្ម តម្រូវឱ្យខេត្តនីមួយៗត្រូវបង្កើតទីកន្លែងបញ្ចេញមតិសាធារណៈក៏ដោយ។ ការបន្តធ្លាក់ចុះនូវសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ មិនមែនត្រឹមតែអ្នកដែលមានបំណងចូលរួមក្នុងបាតុកម្មប៉ុណ្ណោះទេ។ ដូចដែលកម្ពុជាឈានចូលដល់ការបោះឆ្នោតបន្ទាប់ ការធានាថាប្រជាពលរដ្ឋមានលទ្ធភាព និងមានលំហគ្រប់គ្រាន់ក្នុងការបញ្ចេញទស្សនៈ ការជួបជុំ និងការចូលរួមក្នុងការជជែកដេញដោលជាសាធារណៈ គឺជារឿងដ៏សំខាន់។ ដូចដែលអតីតអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជាបានលើកឡើង ការបើកចំហផ្នែកនយោបាយប្រកបដោយអត្ថន័យ ទាមទារឱ្យមានការគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការជួបជុំដោយសន្តិវិធី ព្រមទាំងបង្កើនឱ្យមានការចូលរួមដោយបរិយាបន្ន និងយន្តការត្រួតពិនិត្យ និងតុល្យភាពអំណាចដែលដឹកនាំ

[13] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា៖ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក វីទីត ម៉ុនតាប៊ិន, A/HRC/60/86, ២៣ កក្កដា ២០២៥

ដោយប្រជាពលរដ្ឋ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោកបណ្ឌិត សេង សុវត្ថនា នាយកប្រតិបត្តិ ម.ស.ម.ក តាមរយៈ ទូរសព្ទលេខ +៨៥៥ (០) ១៧ ៥៧០ ៧៦៨ ឬអ៊ីម៉ែល sovathana@cchrcambodia.org